**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៧៥ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១៤១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់យកថ្ងៃទី១៣ខែតុលា រៀងរាល់ឆ្នាំជាទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយទិវាអាស៊ានគ្រប់គ្រងគ្រោះមហន្តរាយ និងទិវាអន្តរជាតិកាត់បន្ថយគ្រោះមហន្តរាយ ដើម្បីៈ

- លើកកម្ពស់ការយល់ដឹងអំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដល់ប្រជាពលរដ្ឋនិងការចូលរួមបញ្ចៀសការបាត់បង់ជីវិត ការខូចខាតបាត់បង់ទ្រព្យសម្បត្តិ ការប៉ះពាល់បរិស្ថាន និងការអាក់ដំណើរការសហគមន៍ សង្គម សេដ្ឋកិច្ច
- អប់រំផ្សព្វផ្សាយអំពីផលវិបាកនៃគ្រោះមហន្តរាយទៅលើសង្គមនិងសេដ្ឋកិច្ច
- បំផុសចលនាចូលរួមទាំងអស់គ្នា ដើម្បីកសាងភូមិ ឃុំ សង្កាត់ ឱ្យមានសុវត្ថិភាពនិងភាពធន់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ ធ្វើការត្រៀមបង្ការ និងការត្រៀមរៀបចំឆ្លើយតបគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- បង្កើនការគាំទ្រពីមហាជនដោយចាត់ទុកការគ្រប់គ្រងគ្រោះមហន្តរាយ គឺជាភារកិច្ចទាំងអស់គ្នា
- បញ្ជ្រាបចំណេះដឹងទូទៅទាក់ទងនឹងវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

**មាត្រា២ .-**

គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការអន្តរជាតិ ផ្នែកឯកជន និងគ្រឹះស្ថានសិក្សានានា ត្រូវចូលរួមបំផុសស្មារតីប្រុងប្រយ័ត្នខ្ពស់ក្នុងការគ្រប់គ្រងនិងទប់ស្កាត់ហានិភ័យគ្រោះមហន្តរាយ។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវរៀបចំទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយសហការជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការអន្តរជាតិ ផ្នែកឯកជន និងគ្រឹះស្ថានសិក្សានានា។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៣ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ